# ព្រះពុទ្ធសាសនា និង ការអប់រំសីលធម៌ខ្មែរ

## ដោយព្រឹទ្ធាចារ្យ ឆេង ផុន (ឆ្នាំ១៩៩៦)




*សម័យឥឡូវនេះ ដោយការលូតលាស់ខាងសម្ភារៈវាខ្លាំងពេកទៅ ក៏លេចឡើងនូវការប្រជេញប្រណាំងទៅរកសមត្ថភាព ដោយការប្រជេញប្រណាំងទៅលើលោកិយ បញ្ហាវាខ្ពស់ពេកទៅ សេចក្តីត្រូវការមានមិនចេះចប់ ទោះសម្ភារៈលូតលាស់យ៉ាងណា ក៏មិនអាចបំពេញសេចក្តីត្រូវការបាន។ យើងមិនអាចបញ្ចប់បាន យើងមិនអាចគ្រប់គ្រាន់ទៅកើត ដូច្នេះទំនាស់ជម្លោះវាក៏កើតឡើងដែរ ។*

*ខ្ញុំព្រះករុណាចេះតែគិតពិចារណា រួចហើយក៏គិតទៅដល់សម័យអង្គរ ដែលគេសាងប្រាសាទបាយ័ន មានកំពូល ៥៤ សុទ្ធតែមានមុខបួនទាំងអស់ ។ មនុស្សដែលមានមុខពីក្រោយ មានប្រាជ្ញាពីក្រោយនោះ ជាមនុស្សដែលគេចផុតពីទោសទាំងឡាយរបស់ជីវិត ។ ប្រហែលជាតិខ្មែរកាលជំនាន់នោះ ដើរទៅណាមកណា មនុស្សសុទ្ធតែមានមុខបួនដូចៗ គ្នាអញ្ចឹងហើយមើលទៅ ។ ខ្ញុំព្រះករុណា ចេះតែគិតយ៉ាងដូច្នេះ ព្រោះកំពូលកណ្តាលតំណាងឲ្យអំណាចកណ្តាល ។ កំពូលរាងកាយ ៥៤ ឯទៀតជាអំណាចរាយរងទាំងអស់ ។ ទ្វារទាំងប្រាំ គឺទល់ដែនយើងទាំងប្រាំប្រក។ សូម្បីតែនៅទល់ដែនបើគិតអំណាចកណ្តាលរហូតដល់ទល់ដែន រហូតទៅដល់ចុងកាត់មាត់ញក ត្រូវតែមានព្រហ្មវិហារធម៌ទាំងអស់ ។ បើអញ្ចឹង ប្រហែលជាព្រះមហាក្សត្រក៏មានព្រហ្មវិហារធម៌ រាស្ត្រក៏មានព្រហ្មវិហារធម៌ អ្នកមានក៏មានព្រហ្មវិហារធម៌ អ្នកក្រក៏មានព្រហ្មវិហារធម៌ អ្នកល្ងង់ក៏មានព្រហ្មវិហារធម៌ អ្នកចេះក៏មានប្រហ្មវិហារធម៌ ។ បើមនុស្សទាំងអស់សុទ្ធតែមានព្រហ្មវិហារធម៌ នៅក្នុងសង្គមមួយទាំងមូល តើសង្គមនោះវាល្អប៉ុនណា? គេឃើញមុខគ្នា សុទ្ធតែញញឹមដោយព្រហ្មវិហារធម៌ទាំងអស់ មើលមុខគ្នាដោយព្រហ្មវិហារធម៌។*







មើលមុខគ្នាមិនឃើញគំនុំ មិនឃើញជាសត្រូវ មិនឃើញជាខ្មាំង ដូច្នេះនាំឲ្យគ្មានការភ័យព្រួយពីរឿងមនុស្សសម្លាប់មនុស្សទេ។ ខ្ញុំព្រះករុណា ចេះតែគិតដល់សម័យរុងរឿង តើគេរុងរឿងអ្វីខ្លះ? សូមមេត្តាពិចារណា។

ដោយខ្ញុំព្រះករុណាជាប់ចិត្តនឹងវប្បធម៌របស់ខ្លួន ក៏ខំរកនឹកថាតើនៅសម័យរុងរឿងគេខ្លាំងខាងអី? គេរុងរឿងអី? គេរុងរឿងខាងសម្ភារៈ? គេរុងរឿងខាងស្មារតី? គេរុងរឿងខាងផ្លូវចិត្ត? ឬក៏គេរុងរឿងទាំងកាយទាំងចិត្ត ទាំងស្មារតី? ខ្ញុំព្រះករុណា ចេះតែគិតពិចារណារិះរកពីការកើតឡើង ការវិវឌ្ឍន៍ ការរីកចំរើន ... ពីការដាំទីងស្រុតចុះដល់កំរិតមួយដែលលែងកែខៃបាន លែងគ្រប់គ្រងបាន។

ទាំងអស់នេះ សុទ្ធតែមានហេតុនិងបច្ច័យរបស់វា។ ប្រាសាទទាំង ១០៨០ សុទ្ធតែសារៈកើតមុនកំណើតទាំងអស់ គ្មានរឿងផ្សងព្រេង គ្មានរឿងចៃសន្យ គ្មានរឿងនឹកស្មានៗ ធ្វើស្មានៗទេ។ និយាយរួមគឺគ្មានស្មានទេ។ ដល់មកឥឡូវវាផ្សងព្រេងនិយម ចៃដន្យនិយមពេក។ នឹកឃើញថា នឹកឃើញធ្វើ នឹកឃើញសំរេច។ ខ្ញុំព្រះករុណាមើល ឃើញថាខុសកាន់តែជ្រៅទៅៗ ។ ប្រៀបធៀបទៅនឹងប្រាសាទទាំង ១០៨០ មិនឃើញមានប្រាសាទណាមួយខុសខ្នាត ខុសក្បួននោះឡើយ ។ រហូតដល់ឥឡូវនេះ ទោះបីជាបច្ចេកទេសលូតលាស់ប៉ុនណា ធរណីមាត្ររីកចំរើនដល់ណាក៏ដោយ ក៏យកទៅគណនាឃើញថា អត់ខុសទាស់តែសោះ។ សព្វថ្ងៃ ខ្ញុំព្រះករុណាយល់ឃើញថា ទាល់តែបង្រៀនខ្មែរឲ្យចេះទ្រឹស្តីហេតុផលឡើងវិញ នោះគឺហេតុផលតាមបែបព្រះពុទ្ធឲ្យខ្មែរដឹង សូម្បីតែការកើតនិងការស្លាប់ ក៏ត្រូវឲ្យដឹងហេតុផលផងដែរ។ ហើយយ៉ាងហោចណាស់ ឲ្យដឹងត្រឹមតែសារៈកើតមុនកំណើតប៉ុណ្ណឹងក៏បានដែរ។ ដូច្នេះ យើងក៏មើលឃើញថាទ្រឹស្តីព្រះពុទ្ធសាសនាជួយយើងសន្ធឹកណាស់ ។

កាលពីថ្ងៃមុននោះ នៅអន្ទង់វិល ខ្ញុំព្រះករុណាបានប្រើពាក្យមួយថា ព្រះធម៌ជាជីវិត ឬជីវិតជាព្រះធម៌? មិនអាចព្រះធម៌នៅផ្សេង ជីវិតនៅផ្សេងបានទេ។ ធ្វើយ៉ាងដូចម្តេចឲ្យព្រះធម៌កើតនៅត្រឹមជីវិតប្រចាំថ្ងៃរបស់យើង

ទើបព្រះធម៌មានប្រយោជន៍ ។ ចុះបើព្រះធម៌នៅដោយឡែកពីជីវិត ជីវិតនៅដោយឡែកពីព្រះធម៌ តើវាទៅជាយ៉ាងណា? វត្តនៅដោយឡែកពីសង្គម សង្គមនៅដោយឡែកពីវត្ត តើនិងទៅជាយ៉ាងណា?



ថ្ងៃមុន ខ្ញុំព្រះ ករុណាជំរាបសម្តេចនាយកថា ខ្មែរយើងពីដើមមានសាលាស្រុកពីរ គឺសាលាស្រុកខាងលោកិយ មានប៉ូសីលមានគុក មានច្រវាក់ មានខ្នោះ មានឃ្នាង, និងសាលាស្រុកមួយទៀត គេហៅថាសាលាស្រុកខាងស្មារតី គ្មានគុក គ្មានច្រវាក់គ្មានខ្នោះ គ្មានឃ្នាងទេ មានតែការអប់រំ ។ ឧទាហរណ៍ តាមប្រពៃណីពីបុរាណ បើមានចោរ  នោះ ព្រះសង្ឃអញ្ជើញចោរទៅវត្តលោកគ្រូចៅអធិការ និយាយនឹងចោរថា "អាត្មាសុំបិណ្ឌបាតរឿងលួច រឿងប្លន់កាប់សម្លាប់  ផឹកស៊ី អាវ៉ាសែ ចាប់ពីថ្ងៃនេះ  សូមញោមឈប់ប្រព្រឹត្តទៀត។  បើចោរព្រមប្រគេនលោក  នូវការប្រព្រឹត្តខុសឆ្គងខាងលើទាំងប៉ុន្មាននេះ ចោរនោះចេញពីវត្តមក ក្លាយជាមនុស្សត្រឹមត្រូវ ។

ចំណែកយើងឥឡូវនេះ យើងខ្វះចៅហ្វាយស្រុកបែបនេះ។ ដូច្នេះរឿងយោនយកកំណើត រឿងឲ្យកំណើតទៅគេ សូមពិចារណាមើល  តើសព្វថ្ងៃនេះយើងរៀបចំខ្លួនសម្រាប់ទៅណា?  និយាយអំពីការអប់រំ  ដូចដែលមានចែងនៅក្នុងប្រធានបទនោះ យើងត្រូវពិភាក្សាគ្នាអំពីព្រះពុទ្ធសាសនាទាក់ទងទៅនឹងការអប់រំ។



កាលពីសម័យអង្គរ កម្មវិធីសិក្សារបស់ព្រះបាទជ័យវរ្ម័នទី៧ កម្មវិធីសិក្សានៅឧត្តមសិក្សាព្រះខ័ន ដែលមានព្រះនាងឥន្ទ្រទេវី ជ័យរាជទេវី ជាបងប្អូនបង្កើតជាសកលវិទ្យាធិការិនី សូមព្រះអង្គជួយស្រាវជ្រាវមើលក្នុងសិលាចារឹកផង តើមានអ្វីខ្លះ។ ខ្ញុំនិងលោកយី ធន់ បាននាំគ្នាស្រាវជ្រាវអំពីភាពរុងរឿងក្នុងសិលាចារឹកនិងកម្មវិធីអប់រំក្នុងសម័យអង្គរ តើគេចាត់ចែងរៀបចំយ៉ាងណា? ទិសរបស់គេមានបី ទី១ គឺច្បាំងឈ្នះខ្លួនឯង, ទី២ ច្បាំងឈ្នះធម្មជាតិ ទី៣ ច្បាំងឈ្នះអ្នកដទៃ។

ម្យ៉ាងវិញ ខ្ញុំបានជំរាបសម្ដេចនាយកផងដែរថា យើងខ្ញីខ្លានឹងការប្រឆាំងឈ្នះខ្លួនឯង យើងខ្ញីខ្លានិងការយកចិត្តទុកដាក់នឹងខ្លួនឯង យើងចង់ឈ្នះអ្នកដទៃខ្លាំងជាងចង់ឈ្នះខ្លួនឯង ឬមួយក៏ចង់ឈ្នះធម្មជាតិខ្លាំងពេក ដោយមិនគិតអំពីជ័យជំនះលើខ្លួនឯង ។ អ្វីៗទាំងអស់ ស្រេចទៅលើមនុស្ស មនុស្សខ្លាំងមនុស្សឈ្នះ ។ ដូចតែដោមាសនិងតែដោយ៉តបានផ្ដាំថាៈ មនុស្សខ្លាំង មនុស្សឈ្នះគឺមនុស្សស្គាល់ចំណុចខ្សោយខ្លួនឯង ជំនះចំណុចខ្សោយខ្លួនឯងបាន ស្គាល់ចំណុចខ្សោយរបស់ខ្មាំង វាយខ្មាំងតាមចំណុចខ្សោយរបស់ខ្មាំង។ ខ្ញុំព្រះករុណា ចេះតែយកសំដីនេះមកគិតយល់ថា នៅពេលបច្ចុប្បន្ននេះ សំដីនេះមានតម្លៃណាស់ ។ ជ័យជំនះដែលពុំវិលត្រឡប់ទៅបរាជ័យ គឺជ័យជំនះលើខ្លួនឯង ។ ចង់ឈ្នះលើអ្នកដទៃបើគេខ្លាំងដែរ ប្រាកដជាបរាជ័យហើយ។ ម្យ៉ាងវិញ ខ្ញុំព្រះករុណាបានជួយជាមួយអ្នកនិពន្ធ (អ្នកកាសែត) ប្អូនដប់ម្ភៃនាក់ ខ្ញុំបានឲ្យយោបល់ថា ប្អូនអើយ ! យើងចាប់ខ្សោយពីរឿងជេរគេនេះតែម្ដង។ កាលដែលខ្មែរខ្លាំង ខ្មែរជេរខ្លួនឯងច្រើនជាងជេរគេ។ កត្តាខាងក្រៅមិនសំខាន់ទេ គឺកត្តាខាងក្នុងទេដែលសំខាន់ជាង។ ការពោលមកទាំងប៉ុន្មាន នេះ គ្រាន់តែចង់ប្រគេនព្រះអង្គជ្រាបប៉ុណ្ណោះ ហើយសូមអភ័យទោស ដោយឥតបានត្រៀម និងចងក្រងឲ្យទៅ ជាប្រព័ន្ធមានទំនាក់ទំនងគ្នារវាងអត្ថន័យនិងអត្ថរូប។ នេះគ្រាន់តែជាគំនិត ដើម្បីផ្សារភ្ជាប់មជ្ឈមណ្ឌលវិបស្សនាជាមួយនឹងពុទ្ធសាសនបណ្ឌិត្យ ដែលជាមិត្តភ័ក្តិធ្លាប់ជួយគ្នាទៅវិញទៅមក។

ខ្ញុំបានឯកភាពគ្នាជាមួយប្អូន យី ធន់ ថា ប្រសិនបើព្រះពុទ្ធសាសនាគ្មានប្រយោជន៍ដល់ជីវិតទេ វានិងរលត់បាត់ទៅហើយ ។ ខ្ញុំព្រះករុណាចេះតែពិចារណាថា យ៉ាងម៉េចបានជាវត្តមួយៗ ឃើញសុទ្ធតែចាស់ៗទៅ ។ ម្យ៉ាងវិញទៀត អ្នកដែលចូលទៅរៀនសមាធិរៀនវិបស្សនា ម៉េចក៏ឃើញសុទ្ធតែយាយៗ និងតាៗ? តើធម៌ព្រះពុទ្ធសំរាប់តែមនុស្សជិតស្លាប់ទៅវិញឬអី ? សុទ្ធតែជាធម៌ផាប់ឬអី ? តើមានធម៌សំរាប់យុវជនឬទេ ? មានធម៌សំរាប់រៀនពូកែឬទេ ? មានធម៌សំរាប់រកស៊ីពូកែឬទេ ? មានធម៌សំរាប់ធ្វើនយោបាយពូកែឬទេ ? មានធម៌សំរាប់ធ្វើប៉ូលីសពូកែឬទេ ? មានធម៌សំរាប់ធ្វើយោធាពូកែឬទេ ? ម៉េចក៏អត់ ? ហើយបើមាន ម៉េចក៏អត់មនុស្សមករៀន ? តើមកពីអ្នកណា? មកពីលោកសង្ឃ? មកពីអ្នកបង្រៀនឬក៏មកពីគេមិនមក? គ្រាន់តែប៉ុណ្ណឹងយើងអាចពិចារណាបានហើយថាម៉េចបានជាអញ្ចឹង?

ដូចខ្ញុំបាននិយាយពីខាងដើមមកហើយថា អ្នកនិពន្ធប្អូនដប់នាក់សរសេរជេរគេពាសវាលពាសកាល ដោយអះអាងថា មកពីអ្នកនេះគេធ្វើបាបអញ្ចេះមក ពីអ្នកធំ មកពីរដ្ឋអំណាច...។ ខ្ញុំប្រាប់ទៅវិញថា ប្អូនឯងយល់ច្រឡំពេញទីហើយ។ ម៉េចក៏ទុកទោសទាំងឡាយផ្ទើយដាក់អ្នកដទៃវិញ? ហើយប្អូនឯងម៉េចក៏រួចខ្លួន? សួរថា បើយើងមិនទទួលតើអ្នកណាជាអ្នកឲ្យបង្ខំយើងទទួលបាន? ឧបមាថា ខ្ញុំមិនខឹងតើអ្នកណាចេះមកធ្វើម៉េចឲ្យខ្ញុំខឹងបាន?

ដូច្នេះការអប់រំហ្នឹងវាជួយទៅដល់សង្គម គឺជួយមនុស្សឲ្យបន្ថយកំហឹង បន្ថយការប្រមាថ នេះចាត់ទុកថាវាសម្បើមណាស់ទៅហើយ។

ក្នុងអង្គប្រជុំថ្ងៃមុន លោកយាយរីណេប៉ាន់ សួរខ្ញុំថា ឥឡូវតាឯងយល់យ៉ាងម៉េចអំពីការបញ្ចូលធម៌ព្រះពុទ្ធទៅក្នុងកម្មវិធីសិក្សារបស់សាលា ដូចយ៉ាងសីលប្រាំ ជាដើម ។ ឯព្រះតេជព្រះគុណ ហេង មណីចិន្តា ក៏បានបំផុសរឿង សីល៥ ទៅក្នុងអប់រំដែរ។ ខ្ញុំព្រះករុណាឲ្យយោបល់ថា ធ្វើឲ្យមែនទែនណ៎ា? ប្រយ័ត្នបង្កឲ្យមានរឿងប្រមាថព្រះណ៎ា? តែធ្វើមិនស្រួល វាក្លាយទៅជារឿងលេងសើច ។ ប្រយ័ត្ន! ខ្មែរលេងអាក្រក់ណាស់។ រឿងនេះត្រូវគិតឲ្យមែនទែន កុំគិតតែពីរឿងសប្បាយ រឿងស្រួលហើយក៏នាំគ្នាបញ្ចូលភ្លាមទៅ ដោយមិនបានពិចារណាអំពីផលវិបាក និងមិនបានត្រៀមលក្ខណៈជាមុន។ បើសព្វថ្ងៃនេះ ត្រូវរវល់តែរកស៊ី គ្រូកំពុងតែលំបាក តើធម៌ហ្នឹងវាចូលទៅដល់ក្មេងយ៉ាងម៉េចទៅ ? តើគេចាប់ពីអ្វីទៅអ្វី ពីណាទៅដល់ណា បើអ្វី ។ ហាក់បីដូចគ្មានបានត្រៀមទុកសោះយ៉ាងនេះ? គំនិតវាល្អមែនហើយប៉ុន្តែ វិធី តើទៅតាមវិធីណា? រួចបើម៉ែឪ មិនទាន់ចេះធម៌ផង ធ្វើម៉េច? វិធីដែលព្រះអង្គហេង មណីចិន្តា ធ្វើដូចជាម្យ៉ាងដែរ ។ ព្រះអង្គហៅក្មេងៗ មករៀនអង់គ្លេស ព្រោះនិន្នាការបច្ចុប្បន្ននេះ ក្មេងៗចង់រៀនអង់គ្លេសណាស់ ។ លោកមានពុទ្ធដីកាថា អាត្មាអាចបង្រៀនភាសាអង់គ្លេសបាន ដោយមិនទាំងយកឈ្នួលទៀតផង ប៉ុន្តែជាថ្នូរ សុំឲ្យក្មេងៗទាំងនោះរៀនធម៌។ សព្វថ្ងៃនេះ ក្រោយពីមានការព្រមព្រៀងពីសិស្សក្មេងៗនោះមក មានអ្នកស្ម័គ្រចិត្តរៀនធម៌ ដូរនឹងភាសាអង់គ្លេសចំនួនដល់ទៅជាង ១.០០០ នាក់ទៅហើយ គេទាំងអស់គ្នាចេះសូត្រធម៌ឥតមានទើសទាក់ឡើយ។ លុះក្មេងៗទាំងនេះរៀនធម៌ចេះសូត្រធម៌ ដល់ត្រឡប់ទៅផ្ទះវិញឃើញថា មានការដូរចរិតខ្លះៗ គឺគេមានសីលធម៌ល្អជាមួយឪពុកម្ដាយ ។ ឃើញដូច្នោះ ម៉ែឪស្រឡាញ់កូន ស្រឡាញ់ទាំងព្រះសង្ឃដែលបានបង្ហាត់បង្រៀនកូន ស្រឡាញ់ទាំងវត្ត ដែលជាទីផ្សព្វផ្សាយព្រះធម៌ ។ នេះជាវិធីមួយបែប សំរាប់បញ្ចូលធម៌ទៅក្នុងសាលា ។ គួរគប្បីពិចារណាថា យើងមិនមែនចេះតែបញ្ចូល ចេះតែបញ្ហានោះទេ ។ ធ្វើបែបនេះ ប្រហែលជាគ្មានប្រយោជន៍អ្វីទេ ។ នេះហើយជារឿងដែលយើងទាំងអស់គ្នាត្រូវពិចារណា ។

